គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD- CWCC - GENEROUS - HROTP - IDA
KID - KKKHRA - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - PDP- PJJ - TASK FORCE - VIGILANCE
#3, St. 158, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Cambodia, Tel/Fax: 023 351415 E-mail: chrac@forum.org.kh


# អនុសាសន៍ស្តីពីសេចក្តីព្រាងវិធានផ្ទៃក្នុងសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦**

**រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា**


**សំរាប់ព័ត៌មានលំអិតសូមទាក់ទង:**

លោក **ធន សារាយ**, ប្រធានសំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគមអាដហុក

ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩

លោក **សុក សំអឿន**, នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩

កញ្ញា **សេង ធារី**, នាយិកាប្រតិបត្តិមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម

ទូរស័ព្ទលេខ: ០១២ ២២២ ៥៥២

លោកស្រី **ណៃ ឪណា**, នាយិកាប្រតិបត្តិវិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ

ទូរស័ព្ទលេខ: ០១១ ៩២៤ ២៨៦

លោកស្រី **ពុង ឈីវកេក**, ប្រធានអង្គការលីកាដូ

ទូរស័ព្ទលេខ: ០១២ ៩៤០ ៦៤៥

លោកស្រី **ពឹង យុកហៀប**, នាយិកាប្រតិបត្តិអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា

ទូរស័ព្ទលេខ: ០១២ ៨២៣ ៤៧៥

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD- CWCC - GENEROUS - HROTP - IDA
KID - KKKHRA - KKKHRDA - KSA - KYA - LAC - LICADHO - OUTREACH - PDP- PJJ - TASK FORCE - VIGILANCE
#3, St. 158, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Cambodia, Tel/Fax: 023 351415 E-mail: chrac@forum.org.kh

## គោរពជូន សមាជិកដ៏ចំណាន១នៃកិច្ចប្រជុំពេញអង្គលើកទី ២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា មានសេចក្តីរីករាយដោយបានកត់សំគាល់ឃើញថា សេចក្តីព្រាងវិធានផ្ទៃក្នុងសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដាក់បញ្ចូលនូវការរីកចំរើនវិជ្ជមានជាច្រើនដែលអាចគំរូមួយដ៏ល្អជាទូទៅសំរាប់ច្បាប់កម្ពុជា។ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមស្វាគមន៏នូវឱកាសក្នុងការចូលរួមចំណែកក្នុងការផ្តល់អនុសាសន៏ ហើយគណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងដំណើរការជាប្រវត្តិសាស្ត្រនេះនឹងអាចជួយឱ្យអង្គជំនុជម្រះវិសាមញ្ញកាន់តែរឹងមាំឡើងថែមទៀត។

ដោយសារការផ្តល់ពេលវេលាដ៏ខ្លីដើម្បីរៀបចំធ្វើអនុសាសន៏ទៅលើបទបញ្ជាផ្ទៃក្នុងនេះ និងដោយចំពេលរៀបចំពិធីបុណ្យជាតិផ្សេង១ផងនោះ គណៈកម្មាធិការប្រព្រឹត្តិកម្មសូមរក្សាសិទ្ធិក្នុងការបន្តជួយផ្តល់អនុសាសន៏បន្ថែមនៅពេលខាងមុខទៀត។ លើសពីនេះទៀតគណៈកម្មាធិការប្រព្រឹត្តិកម្មស្នើដល់អង្គជំនុំជម្រះវិសាមញ្ញដើម្បីធានាថា អង្គការក្រៅរដ្ឋាភិបាលនឹងចូលរួមក្នុងការព្រាងវិធាន និងការធ្វើវិសោធនកម្មនានាទៅលើនិតិវិធីទាំងនេះឱ្យបានច្រើនថែមទៀត តាមដែលអាចធ្វើទៅបាន។

ទាក់ទិននឹងសេចក្តីព្រាងវិធានផ្ទៃក្នុងនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម មានការចាប់អារម្មណ៏ទៅលើនូវចំណុចមួយចំនួនសំខាន់១ដូចតទៅ:

១- ការបន្ថែមអំណាចយុត្តាធិការទៅឱ្យអង្គបុរេជំនុំជម្រះ

២- ការសំរេចដោយសំឡេងភាគច្រើនលើសលប់

៣- ការការពារសិទ្ធិរបស់ជនជាប់ចោទ

៤- ការធានាឱ្យមានការចូលរួមរបស់ជនរងគ្រោះ ការការពារជនរងគ្រោះ និងការជួសជុលសំណង

៥- ការផ្តល់ការចូលរួមសាធារណៈឱ្យកាន់តែទូលំទូលាយទៅលើសេចក្តីសំរេចរបស់តុលាការ

៦- ការចៀសវាងមិនឱ្យការជំនុំជម្រះកំបាំងមុខ

៧- ការបញ្ជាក់ឱ្យច្បាស់លាស់អំពីតួនាទីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

៨- ការធានាទៅលើគុណភាពល្អនៃការបកប្រែភាសា

៩- ការការពារបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ ជនរងគ្រោះ សាក្សី និង ជនជាប់ចោទពីបណ្តឹងព្រហ្មទណ្ឌចំពោះការជេរប្រមាថ និងបរិហាកេរ្តិ៍

អនុសាសន៏ផ្សេងដទៃទៀតទាក់ទិននឹងវិធានពិសេសមួយចំនួនក៏មានភ្ជាប់មកជាមួយដែរ។

ជាចុងក្រោយនេះ គណៈកម្មាធិការប្រព្រឹត្តិកម្មក៏បានកត់សំគាល់ឃើញនូវភាពខុសគ្នាមួយចំនួន១នៅក្នុងសេចក្តីព្រាងវិធានផ្ទៃក្នុងជាភាសាអង់គ្លេស, ភាសាបារាំង និងភាសាខ្មែរ ដែលត្រូវបានផ្តល់ឱ្យធ្វើអនុសាសន៏ដែរ។ គណៈកម្មា-ធិការប្រព្រឹត្តិកម្ម សង្ឃឹមថា នៅពេលដែលវិធានផ្ទៃក្នុងនេះត្រូវបានអនុម័ត ការបកប្រែភាសាដ៏ត្រឹមត្រូវមួយនឹងត្រូវបានផ្តល់ឱ្យផងដែរ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម ទន្ទឹងរងចាំធ្វើការក្នុងន័យជួយស្ថាបនា ជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញជាបន្តទៀតនៅអំឡុងឆ្នាំខាងមុខ និងសូមជូនពរដល់កិច្ចប្រជុំពេញអង្គនាពេលខាងមុខនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

## ១. អង្គបុរេជំនុំជម្រះ

### *វិធាន ២១ និងវិធាន ៧៤. អំណាចយុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ*

គណៈកម្មាធិការប្រព្រឹត្តិកម្ម ចង់ឃើញអង្គជំនុំជម្រះអនុម័តនីតិវិធីមួយដែលមានប្រសិទ្ធភាពខ្ពស់តាមដែលអាចធ្វើទៅបានដោយគោរពតាម ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ, កិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងសិទ្ធិរបស់ជនជាប់ចោទ។

ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៅមានការព្រួយបារម្ភថា សេចក្តីព្រាងវិធានផ្ទៃក្នុងបច្ចុប្បន្នអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះអាចធ្វើឱ្យរាំងស្ទះរឿងក្តីមិនឱ្យទៅមុខបាន។វានឹងអាចទៅជារឿងរ៉ាវប្រវត្តិសាស្ត្រមិនល្អមួយសំរាប់យុត្តិធម៌នៅកម្ពុជា ក្នុងករណីដែលសេចក្តីសំរេចរបស់ចៅក្រមស៊ើបអង្កេតបញ្ជូនរឿងទៅជម្រះត្រូវបានធ្វើឱ្យរាំងស្ទះនៅក្នុងសវនាការជាសំងាត់របស់អង្គបុរេជំនុំជម្រះ ជាពិសេសក្នុងករណីដែលរឿងនេះអាចសំរេចបានដោយសំឡេងគាំទ្ររបស់ចៅក្រមភាគច្រើនរបស់អង្គបុរេជំនុជម្រះនោះ។

ដូចនេះ អង្គបុរេជំនុំជម្រះ គួរតែមានអំណាចដូចខាងក្រោមនេះ

- ដោះស្រាយការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និង ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដូចដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង។
- ពិនិត្យមើលឡើងវិញអំពីការងារស៊ើបអង្កេតដូចដែលបានចែងនៅក្នុងវិធាន ៧៤.៣ ខ, គ។
- ដោះស្រាយទំនាស់រវាងការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត និងការិយល័យសហព្រះរាជអាជ្ញាអំពីបុគ្គល និងបទល្មើសដែលត្រូវចោទប្រកាន់ (វិធាន ៧៤.២)។
- មើលឡើងវិញអំពីបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយជនត្រូវចោទ ទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន និងការធានាឱ្យនៅក្រៅឃុំ (វិធាន ៧៤.៣ ង)។ ប៉ុន្តែសេចក្តីសំរេចទាំងនោះ គួរតែជាសេចក្តីសំរេចចុងក្រោយ និងមិនគួរត្រូវបានគេយកមកពិនិត្យមើលឡើងវិញដោយសាលាដំបូង និងតុលាការកំពូលនោះឡើយ (វិធាន ៨០.៥)។ វិធានផ្ទៃក្នុងនាពេលបច្ចុប្បន្ននេះ កំណត់នូវការពិនិត្យមើលឡើងវិញជា ៤ ថ្នាក់ទាក់ទិននឹងការកំណត់ការឃុំខ្លួនដែលនេះមិនមែនជាការចាំបាច់ក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទនោះឡើយ។

អង្គបុរេជំនុំជម្រះមិនគួរមានអំណាចដូចខាងក្រោមនេះឡើយ

- ដោះស្រាយបញ្ហាយុត្តាធិការទាក់ទិននឹងអង្គជំនុំជម្រះទាំងមូល។ រាល់បញ្ហាស្តីពីនិត្យានុកូលភាព និងយុត្តាធិការ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ ដូចនេះបញ្ហាទាំងនេះគួរតែត្រូវបានយកទៅដោះស្រាយនៅសាលាដំបូង ដោយមានការប្តឹងឧទ្ធរណ៍បន្តទៀតទៅតុលាការកំពូល (វិធាន ៧៤.៣ ក)។
- ពិនិត្យមើលឡើងវិញអំពីការប្តឹងទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជម្រះដោយជនជាប់ចោទ។ គណៈកម្មា-ធិការប្រព្រឹត្តិកម្មយល់ឃើញថា វិធានផ្ទៃក្នុងនេះតំរូវឱ្យសហចៅក្រមស៊ើបអង្កេតជំរាបជូនដល់គ្រប់ភាគីទាំងអស់នៅពេលដែលគេបានធ្វើការស៊ើបអង្កេតពេញលេញរួចហើយ។ សំនុំរឿងរបស់គេ គួរតែបញ្ជូនដល់គ្រប់ភាគីទាំងអស់ ព្រមទាំងកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេល

ដែលសេចក្តីសំរេចចុងក្រោយដើម្បីចោទប្រកាន់បានធ្វើឡើង ដូចនេះសេចក្តីសំរេចនោះគួរតែមិនអនុញ្ញាតឱ្យគេមើលឡើងវិញដោយតុលាការណាមួយបានឡើយ ។ គណៈកម្មាធិការប្រព្រឹត្តិកម្មបានកត់សំគាល់ទៅលើទ្រឹស្តីស្តីពីភាពស្មុគស្មាញនៃដីកាបញ្ជូនរឿងទៅជម្រះ (Theory of Complex Indictments) ដូចនេះ ក្នុងករណីដែលដីកាបញ្ជូនរឿងឱ្យទៅជម្រះចុងក្រោយ ដោះស្រាយទៅលើបញ្ហាជាច្រើន (ដូចជាសេចក្តីសំរេចមិនបញ្ជូនទ្រព្យសម្បត្តិមកឱ្យជនជាប់ចោទវិញ) នោះបញ្ហាទាំងនោះអាចត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ នៅពេលសំនុំរឿងដែលបង្ហាញនៅក្នុងដីកានេះមិនបន្តទៅដល់ការកាត់សេចក្តី ។

ការព្រួយបារម្ភចំបងនោះអំពីចំនុចនេះ គឺថាអង្គបុរេជំនុំជម្រះមិនត្រូវអនុញ្ញាតឱ្យធ្វើឱ្យរាំងស្ទះ ឬបញ្ឈប់រឿងក្តីណាមួយមិនឱ្យឈានទៅដល់ការកាត់សេចក្តីបានឡើយ ។

***វិធាន ៧៧.៥. ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញប្រព្រឹត្តឡើងដោយសំងាត់***

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមស្នើសុំឱ្យអង្គជំនុំជម្រះវិសាមញ្ញអនុម័តនីតិវិធី ដែលតំរូវឱ្យអង្គបុរេជំនុំជម្រះដំណើរការជាសាធារណៈ ។

## ២. ការសំរេចដោយសំឡេងភាគច្រើនលើសលប់

***វិធាន ១៦, ១៨, និង ៧៧. សេចក្តីសំរេចដោយសំឡេងភាគច្រើនលើសលប់***

នៅក្នុងការពន្យល់ Footnote ទី៩ និងវិធាន ៧៧.៩ អ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងនេះ បានដឹងថា ការដែលមានប្រព័ន្ធបោះឆ្នោះដោយសំឡេងភាគច្រើនលើសលប់នេះ គឺផ្តោតទៅលើបញ្ហា ជាជាងការសំរេចថា មានពិរុទ្ធ ឬគ្មានពិរុទ្ធសំរាប់រឿងដែលមិនវិជ្ជមានដែលវាមានជំលោះផលប្រយោជន៍ចំនួនពីរដូចដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង គឺថា ទី១- ការចោទប្រកាន់បន្តទៅមុខបាន និង ទី២-ការគោរពសិទ្ធិជនជាប់ចោទ ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម គាំទ្រនូវសំណើដែលថា ក្នុងករណីដែលសំឡេងភាគច្រើនលើសលប់របស់ចៅក្រមមិនអាចសំរេចបាន (ទៅលើបញ្ហា ជាជាងទៅលើការមានពិរុទ្ធ ឬការគ្មានពិរុទ្ធ) ដូចនេះការចោទប្រកាន់នៅតែបន្ត។ សំឡេងភាគច្រើនលើសលប់នេះមិនត្រូវយកមកប្រើជាមធ្យោបាយ ដើម្បីធ្វើឱ្យរាំងស្ទះដល់ការងារស៊ើបអង្កេត ឬដំណើរការទៅមុខបានឡើយ ។ គណៈកម្មាធិការប្រព្រឹត្តិកម្មមានគំនិតមួយគឺថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានគេការពារ ដោយសារតែប្រព័ន្ធបោះឆ្នោតដោយសំឡេងភាគច្រើនលើសលប់នេះ ស្ថិតនៅក្នុងការសំរេចថា មានពិរុទ្ធ ឬគ្មានពិរុទ្ធ ជាមួយនឹងការថ្លឹងថ្លែងគ្នាដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទច្រើនជាង ។

## ៣. សិទ្ធិរបស់ជនជាប់ចោទ

គណៈកម្មាធិការប្រព្រឹត្តិកម្មនៅមានកង្វល់ថា អង្គជំនុំជម្រះវិសាមញ្ញមិនបានការពារឱ្យពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ ។ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាមានសង្ឃឹមថា តុលាការនេះនឹងផ្តល់នូវគំរូអំពីការប្រព្រឹត្តយ៉ាងល្អចំពោះជនជាប់សង្ស័យ, ជនដែលត្រូវចោទប្រកាន់ និងជនជាប់ចោទនៅក្នុងដំណើរការព្រហ្មទណ្ឌ ។

***វិធាន ១២. មេធាវីការពារជនជាប់ចោទ***

វិធានផ្ទៃក្នុងគួរបញ្ជាក់ឱ្យបានច្បាស់ថា មេធាវីបរទេស ដែលធ្វើជាសហមេធាវី អាចធ្វើការប្រកបដោយប្រសិទ្ធិ ភាព និងដោយឯករាជ្យជាមួយមេធាវីកម្ពុជាជាដៃគូរ ។ វិធាននេះគួរមិនតំរូវឱ្យមេធាវីកម្ពុជាធ្វើជាមេធាវីដឹកនាំឡើយ ។ ក្នុងករណីតំរូវឱ្យចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា វាមិនគួរឱ្យមានការកំហិត ឬលក្ខខណ្ឌផ្សេង១ចំពោះមេធាវីបរទេសឡើយ ។ ក្នុងករណីដែលបញ្ជីនៃមេធាវីការពារដែលត្រូវបានអនុញ្ញាតត្រូវបានបង្កើតឡើង ដូចនេះវិធាននេះ គួរបញ្ជាក់ឱ្យបានច្បាស់ចំនួនអប្បបរមានៃមេធាវីនៅក្នុងបញ្ជីនោះ ដើម្បីធានាឱ្យមានការជ្រើសរើសអ្នកតំណាងពិតប្រាកដ ។

***វិធាន ២៦. សេចក្ដីថ្លែងការណ៍ទទួលបានដោយការបង្ខិតបង្ខំ***

គណៈកម្មាធិការប្រព្រឹត្តិកម្មសូមស្វាគមន៍ចំពោះបទប្បញ្ញត្តិរបស់វិធាន ២៦.៣ ដែលការពារមិនឱ្យមានការ បង្ខិតបង្ខំទៅលើរូបរាងកាយ ឬការគំរាមកំហែងណាមួយ។ ទោះបីជាយ៉ាងនេះក៏ដោយ វិធាននេះគួរបញ្ជាក់ថាតើសេចក្ដីថ្លែងការណ៍បានទទួលដោយបង្ខិតបង្ខំ និងការគំរាមកំហែងបែបនេះ គេអាចយកប្រើប្រាស់សំរាប់គោលបំណងផ្សេងទៀត ដូចជា ដីកានាំខ្លួនទៅជម្រះជាដើម។ គោលជំហររបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម គឺថា សេចក្ដីថ្លែងការណ៍ដែលទទួលបានដោយបង្ខិតបង្ខំមិនអាចត្រូវបានគេយកមកប្រើប្រាស់ក្នុងគោលបំណងអ្វីមួយបានឡើយ។

***វិធាន ២៩. ការបោះបង់សិទ្ធិមានវត្តមានមេធាវីការពារ***

វិធានផ្ទៃក្នុង គួរបញ្ចូលនូវស្ដង់ដារមួយថាៈ ការបោះបង់សិទ្ធិមានវត្តមានមេធាវីការពារ ត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត និងបានដឹងជាមុន។

***វិធាន ៣៣ និង៨៨.១. ការសួរជនជាប់ចោទ***

វិធានផ្ទៃក្នុង មិនបានកំណត់និយមន័យ "សាក្សី " នោះទេ ដូចនេះវាមិនទាន់ច្បាស់ថាតើវិធាន ៣៣ អាចយកទៅអនុវត្តបានទៅលើជនជាប់ចោទដែលផ្ដល់សក្ខីកម្មបានដែរឬយ៉ាងណានោះទេ។ វិធាន២៨.៤ស្នើថាពាក្យថា "សាក្សី " មិនរាប់បញ្ចូលជនជាប់ចោទទេនោះ ដូចនេះមានន័យថា វាមិនទាន់មានបទដ្ឋានណាមួយដើម្បីការពារសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងរបស់ជនជាប់ចោទឡើយ។

កិច្ចព្រមព្រៀងដែលបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ច្បាស់ថា កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវតែយកមកអនុវត្តតាមដោយគោរពចំពោះសិទ្ធិរបស់ជនជាប់ចោទ។ មាត្រា ១៤.៣ ឆ. នៃកតិកាសញ្ញានេះចែងថាៈ ជនគ្រប់រូប “មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ ” ឡើយ។

វិធានផ្ទៃក្នុងណាដែលអនុញ្ញាតឱ្យសាកសួរជនជាប់ចោទអាចជាការរំលោភទៅលើសិទ្ធិនេះ។ ជនជាប់ចោទគួរត្រូវបានគេប្រាប់អំពីសិទ្ធិរបស់គេដូចដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ហើយមិនគួរអនុញ្ញាតឱ្យបដិសេធឆ្លើយនូវសំណួរទាំងឡាយដែលសួរដោយចៅក្រម ឬព្រះរាជអាជ្ញា ឬក៏មេធាវីរបស់ភាគីរដ្ឋប្បវេណីឡើយ។

***វិធាន ៣៤. សាក្សីសំងាត់***

សាក្សីសំងាត់ជាញឹកញាប់មានទាក់ទងទៅនឹងការរំលោភបំពានដោយរដ្ឋាភិបាល។ ដំណោះស្រាយនឹងបញ្ហានេះអំពាវនាវឱ្យមានការពិនិត្យពិច័យ ដែលថ្លឹងថ្លែងយ៉ាងហ្មត់ចត់រវាងសិទ្ធិជនជាប់ចោទ និងសន្តិសុខសាក្សី។ គណៈកម្មាធិការប្រព្រឹត្តិកម្មលើកទឹកចិត្តឱ្យអង្គជំនុំជម្រះវិសាមញ្ញអនុម័តនូវបទដ្ឋានដែលច្បាស់ជាងនេះស្ដីពីការប្រើប្រាស់សាក្សីសំងាត់ ។

***វិធាន ៥៥. ការឃាត់ខ្លួននៅនគរបាល***

ព្រះរាជអាជ្ញាមិនអាចសាកសួរជនជាប់ចោទដោយគ្មានវត្តមានមេធាវីរបស់គេបានទេ វិធាននេះអនុញ្ញាតឱ្យមានពេលវេលាត្រឹមតែ៣០នាទីប៉ុណ្ណោះដើម្បីពិគ្រោះយោបល់ (ដំណាក់កាលមុនពេលសាកសួរ)។ ជនជាប់សង្ស័យត្រូវតែបានប្រាប់នូវសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ និង សិទ្ធិមានមេធាវីការពារ ហើយមេធាវីត្រូវតែមានវត្តមានព្រមទាំងអាចផ្ដល់ប្រឹក្សានៅគ្រប់ពេលសាកសួរ ។

លើសពីនេះទៀត គណៈកម្មការប្រព្រឹត្តិកម្មមានអនុសាសន៍ថា ជនជាប់ឃុំឃាំងត្រូវទទួលបានការពិនិត្យពីគ្រូពេទ្យតាមរយៈសិទ្ធិដែលមានក្នុងដំណាក់កាលឃាត់ខ្លួននៅនគរបាល។ គ្រូពេទ្យអាចធានាការគោរពកាតាព្វកិច្ចជាមូលដ្ឋាន ដើម្បីបង្កាការគំរាមកំហែងតាមរយៈការសង្កេតមើលលក្ខខណ្ឌសុខភាពនៃជនជាប់ឃុំឃាំងនៅមុននិងបន្ទាប់ពីការឃុំឃាំង (មាត្រា ១២ (២) នៃបទប្បញ្ញត្តិអន្តរកាល គោលការណ៍ ២៤ នៃគោលការណ៍គ្រឹះដើម្បីការពាររាល់បុគ្គលដែលស្ថិតក្រោមរាល់

ទម្រង់នៃការឃុំឃាំង រឺ ពន្ធនាគារ) ។ បច្ចុប្បន្ននេះ វិធាន ៥៥ មិនបានបញ្ចូលការធានាទាំងនេះទេ ដែលគោលការណ៍គ្រាន់តែបញ្ជាក់ថា សហព្រះរាជអាជ្ញា " អាចបង្គាប់ថាជនជាប់ឃុំឃាំងអាចត្រូវពិនិត្យដោយគ្រូពេទ្យ " ដោយមិនផ្តល់លទ្ធភាពឱ្យជនជាប់ឃុំឃាំង រឺ គ្រួសារអាចស្នើសុំការពិនិត្យសុខភាពដោយឯករាជ្យបានឡើយ ។

### *វិធាន ៥៥. និង វិធាន ៦០. ការជូនដំណឹងពីជនដែលជាប់សង្ស័យ*

វិធានស្តីពីការជូនដំណឹងពីជនដែលជាប់សង្ស័យបច្ចុប្បន្ននេះ ស្ថិតនៅរាយប៉ាយក្នុងវិធានផ្ទៃក្នុងនេះ។ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវចំណុចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្មសំណូមពរឱ្យមានការអនុម័តជាបទដ្ឋាន ជាក់លាក់មួយនៅក្នុងវិធាននេះ (វិធាននៃបទបញ្ជាផ្ទៃក្នុងនៃជំនុំជម្រះវិសាមញ្ញ) ។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាសូមស្នើឡើងថា " បុគ្គលម្នាក់មានសិទ្ធិទទួលបានការជូនដំណឹងថាមានហេតុផលជាច្រើន ដែលអាចឱ្យជឿរបានថាបុគ្គលនេះបានប្រព្រឹត្តបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ នៅមុនពេលសាកសួរ រឺនៅពេលភ្លាម១ដែលមានភស្តុតាងលេចឡើងនៅក្នុងពេលសាកសួរ "។ នៅពេលជាមួយគ្នានេះ បុគ្គលនេះក៏ត្រូវបានទទួលការជូនដំណឹងពីសិទ្ធិរបស់ខ្លួនដើម្បីទទួលបានមេធាវីការពារដោយមិនគិតកំរៃ និង សិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ ។

ជំហររបស់គណៈកម្មាធិការប្រព្រឹតិកម្ម គឺថា បទប្បញ្ញត្តិនេះគឺត្រូវតែតំរូវឱ្យមាន ដើម្បីបន្ថែមទៅលើការការពារសាក្សី ដែលមានចែងនៅក្នុងវិធាន ៣៣ ។

### *វិធាន ៨០ ការឃុំឃាំងបណ្តោះអាសន្នដល់ជនជាប់ចោទ*

កថាខណ្ឌ ១ ដែលអនុញ្ញាតឱ្យមានការឃុំឃាំងបណ្តោះអាសន្នត្រូវយោងទៅលើវិធានរង ២ និង វិធាន ៦៦.៦ខ (រយៈពេលឃុំឃាំងសរុបមិនអាចលើសពី ៣ ឆ្នាំ) ។

### *វិធាន ៨៦ វិធាននៃភស្តុតាង*

កឋាខណ្ឌ ២ ចែងថា " រាល់សេចក្តីសំរេចត្រូវផ្អែកទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងប៉ុណ្ណោះ រឺ ភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះហើយត្រូវបានជាកម្មវត្ថុនៃការសួរដេញដោល"។

ការណ៍នេះមានភាពមិនច្បាស់លាស់ថា តើពតិមាននៅក្នុងសំណុំរឿង (ដែលភាគីចុងចោទមិនបានបង្ហាញដើម្បី រឺ មិនអាចតទល់បាន) អាចធ្វើជាមូលដ្ឋាននៃសេចក្តី សំរេច (វិធាន ៥៩.៨) ។ បើសិនជាដូច្នេះមែន វានឹងផ្ទុយពីគោលបំណងដែលបានលើកឡើងថានឹងឱ្យមាននីតិវិធីដែលដាក់ឱ្យមានការសួរដេញដោលគ្នាទៅវិញទៅមក (វិធាន២៦.១.ក) និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ ១៤.៣ ង ។ គណៈកម្មាធិការសិទ្ធិមនុស្សបានផ្តល់អនុសាសន៍ជាទូទៅស្តីពីវិធាននេះ (១៤.៣.ង) ចែងថា: " បទប្បញ្ញត្តិនេះត្រូវបានរៀបចំឡើងដើម្បីធានាដល់ជនជាប់ចោទ នូវអំណាចផ្លូវច្បាប់ក្នុងលក្ខខណ្ឌស្មើគ្នា ក្នុងការបង្ខំឱ្យមានការចូលរួមរបស់សាក្សី និងក្នុងការសួរដេញដោល ឬសួរដជីកទៅសាក្សីណាដែលអយ្យការមាន " ។

សិទ្ធិដើម្បីតទល់នឹងសាក្សីអាចនឹងមិនត្រូវបានបំពេញនៅដំណាក់កាលស៊ើបអង្កេតនៅក្នុងនីតិវិធីនេះ ដោយហេតុថាវិធាននេះ អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតជាបឋមសម្ភាសន៏ជូនដំណឹងចោទប្រកាន់ជនជាប់ចោទ ក្រោយពីបានបញ្ចប់ការស៊ើបអង្កេតដ៏ធំធេងមក ។

### *វិធាន ៨៨.២ ៨៩.២-៣ ១០៨.៥. ការសាកសួរសាក្សីនៅក្នុងបន្ទប់សវនាការ*

សហព្រះរាជអាជ្ញា និង មេធាវីជនជាប់ចោទត្រូវមានសិទ្ធិសាកសួរដោយពេញលេញនូវរាល់សាក្សី និង ជនជាប់ចោទ (បើសិន ត្រូវបានហៅមកដោយភាគីចុងចោទ) ដោយមិនចាំបាច់សុំការអនុញ្ញាតពីតុលាការ ។ នេះជាធាតុផ្សំចាំបាច់នៃនីតិវិធីដែលដាក់ឱ្យមានការសួរដេញដោលគ្នាទៅវិញទៅមក ( អាណាប័ក្រ ) ( វិធាន ២៦.១.ក ) ។

ការណ៍នេះអាចនឹងផ្ទុយពីផលប្រយោជន៍នៃយុត្តិធម៌ ដែលផ្តល់ឱ្យប្រធានតុលាការនូវអំណាចដាច់មុខ ដើម្បីកំរិតការសាកសួរ។ ជាវិធានការចុងក្រោយ វិធានត្រូវអនុញ្ញាតឱ្យអង្គជំនុំជម្រះពិនិត្យឡើងវិញនូវរាល់សំណួរ និង អនុញ្ញាតនូវសំណួរប្រព្រឹត្តទៅដោយមិនបាច់មានការសំរេចដោយមតិភាគច្រើនដើម្បីបញ្ឈប់នូវការសួរនោះ ។

***វិធាន ១០៩.៤ ប្រសិទ្ធិភាពនៃបណ្តឹងសារទុក្ខ***

បច្ចុប្បន្ន វិធាននេះបានអនុញ្ញាតឱ្យអង្គជំនុំជម្រះកំពូលអាចពិនិត្យអង្គហេតុ និងអង្គច្បាប់នៅពេលដែលជនជាប់ចោទត្រូវបានរកឃើញថាគ្មានទោសដោយអង្គជំនុំជម្រះដំបូង។ អង្គជំនុំជម្រះកំពូលអាចកំណត់ជាដំបូងនូវទោសកំហុសដោយមិនចាំបាច់មានបណ្តឹងសារទុក្ខ។ ការនេះបំពាននឹងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៤.៥ ដែលនិយាយថា "មនុស្សម្នាក់ៗដែលត្រូវបានរកឃើញថាមានទោសចំពោះបទល្មើសមួយត្រូវមានសិទ្ធិដើម្បីឱ្យតុលាការជាន់ខ្ពស់ជាងពិនិត្យឡើងវិញអំពីទោសកំហុស និងទណ្ឌកម្មរបស់ខ្លួនស្របទៅច្បាប់" ។ ( ត្រូវមានសេចក្តីបញ្ជាក់បន្ថែម )

ការលាតត្រដាងនៃភស្តុតាងដោះបន្ទុកវិធានផ្ទៃក្នុងនេះគួរកត់សំគាល់យ៉ាងជាក់លាក់នូវតម្រូវការដែលថា អយ្យការត្រូវប្រគល់មកឱ្យភាគីចុងចោទនូវភស្តុតាងដោះបន្ទុកនាពេលដ៏ឆាប់បំផុតដែលអាចធ្វើបាន ។

ចំពោះការកាត់ទោសពីរដងវិធាននេះគួរកត់សំគាល់ជនជាប់ចោទមិនអាចត្រូវបានកាត់ពីរដងចំពោះបទល្មើសដដែលដោយរដ្ឋាភិបាលដដែលឡើយ ។

ជំនួយការដែលមិនមានប្រសិទ្ធិភាពរបស់មេធាវីជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីប្រកបដោយពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តី ។ ជាទូទៅច្បាប់មិនតម្រូវឱ្យមេធាវីជនជាប់ចោទមានឱកាសស្មើគ្នាដើម្បីត្រៀមរៀបចំការពារក្តីឡើងដរាបណាជនជាប់ចោទត្រូវ បានផ្តល់ឱ្យនូវមេធាវីដែលផ្តល់ជំនួយការដ៏មានប្រសិទ្ធិភាព ។

ការការពារក្តីដោយខ្លួនឯងវិធាននេះគួរតែបញ្ជាក់ថាតើជនជាប់ចោទអាចធ្វើការការពារក្តីដោយខ្លួនឯងបានដែរទេ ។ វិធាននេះគួរតែបញ្ជាក់ពីបទដ្ឋានមួយដើម្បីវិនិច្ឆ័យពីសមត្ថភាពរបស់ជនជាប់ចោទ ។ វិធាននេះ គួរតែអនុញ្ញាតឱ្យមានជំនួយការដោយមេធាវី (ដោយការជ្រើសរើសដោយខ្លួនឯង) នៅក្នុងករណីដែលជនជាប់ចោទកំពុងការពារខ្លួនដោយខ្លួនឯង ។

## ៤. ការចូលរួមរបស់ជនរងគ្រោះ ការការពារជនរងគ្រោះ និងការជួសជុលការខូចខាត

គណៈកម្មាធិការប្រព្រឹត្តិកម្មសូមសរសើរចំពោះការប្តេជ្ញាចិត្តនៃវិធាន ដែលបញ្ចូលជនរងគ្រោះទៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ។ ការចូលរួមពីសំណាក់ជនរងគ្រោះនឹងជួយផ្សារភ្ជាប់រវាង តុលាការនឹងប្រជាជន ហើយនិងផ្តល់ឱ្យជនរងគ្រោះនូវសំឡេងមួយនៅក្នុងដំណើរការដ៏សំខាន់នេះ ។ ជនរងគ្រោះកម្ពុជា ធ្លាប់បានរង់ចាំអស់រយៈពេលដ៏យូរលង់ ដើម្បីមើលលទ្ធផលចុងក្រោយនៃបទល្មើសនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យ ហើយ ដើម្បីឆ្លើយនឹងចម្ងល់ថាតើ ហេតុអ្វីបានជាបទល្មើសនេះកើតមានឡើង។ ដំណើរការកាត់ក្តីនេះគួរតែឆ្លើយតបនឹងតំរូវការ របស់ជនទាំងនោះជាអតិបរិមាតាមដែលអាចធ្វើទៅបាន ។ ប៉ុន្តែគណៈកម្មាធិការប្រព្រឹត្តកម្មចង់ឱ្យមានការធានាថា ជនរងគ្រោះមានឱកាសដ៏មានន័យដើម្បីចូលរួមនៅក្នុងដំណើរការជាប្រវត្តិសាស្ត្រនេះ ។ ដូច្នេះនីតិវិធីបណ្តឹង និងការចូលរួមពីសំណាក់ជនរងគ្រោះតាមរយៈបបណ្តឹងរដ្ឋប្បវេណីទាមទារឱ្យមានការពិចារណា ។

វិធានបន្ថែមៗទៀតចាំបាច់ត្រូវមានដើម្បីគូសបញ្ជាក់អំពីតួនាទីរបស់អង្គការ មិនមែនរដ្ឋាភិបាលនៅក្នុងជួយ សម្រួលឱ្យមានការចូលរួមពីសំណាក់ជនរគ្រោះ ។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាអន្ទះសារដើម្បីជួយដល់តុលាការនៅក្នុងបញ្ហានេះទៅតាមកំរិតធនធានដែលផ្តល់ឱ្យ ។ យើងស្នើសុំថាអង្គជំនុំជម្រះវិសាមញ្ញបញ្ចូលអង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងដំណើរការសេចក្តីវិធាននានា ដែលទាក់ទងនឹងតួនាទីនៃអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការនេះផងដែរ។

### ***វិធាន ២៧ បណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ***

ប្រព័ន្ធដែលឱ្យមានភាគីរដ្ឋប្បវេណី ដូចដែលមានចែងនៅក្នុងវិធាននេះមិនបានផ្តល់នូវឱកាសដ៏មានន័យដើម្បីឱ្យជនរងគ្រោះចូលរួមនៅក្នុងដំណើរការនេះឡើយ ។ ការកំរិតជាក់ស្តែងដែលភាគច្រើនបំផុត នៃជនរងគ្រោះកម្ពុជាអាចធ្វើដាក់នូវពាក្យសុំជាលាយលក្ខណ៏អក្សរស្វែងរកមេធាវី រឺទៅកាន់តុលាការនៅឆ្ងាយពីលទ្ធភាពដែលអាចធ្វើទៅបាន ។ ៨៤ ភាគរយនៃប្រជាជនកម្ពុជារស់នៅតំបន់ជនបទ ដែលបច្ចុប្បន្នមានការយល់ដឹងតិចតួចចំពោះអង្គជំនុំជម្រះវិសាមញ្ញ ។ លើសពីនេះ ទៅទៀតអត្រាអនក្ខរភាព គឺខ្ពស់មែនទែន ដែលមានស្ត្រី ៤៥ភាគរយ និង បុរស ២៥ភាគរយ ជាអនក្ខរជនទាំងស្រុង ហើយ ៧១ ភាគរយនៃស្ត្រី និង ៥០ ភាគរយនៃបុរសជាអនក្ខរជន។ ៣៥ ភាគរយនៃប្រជាជនកម្ពុជា រស់នៅដោយមានចំណូលតិចជាង ០.៤៥ ដុល្លាក្នុងមួយថ្ងៃ ។

ការកំរិតជាក់ស្តែងនេះ អាចបង្កឱ្យមានការលំបាកដល់ជនរងគ្រោះនៃអំពើព្រៃផ្សៃនេះ ដើម្បីចូលរួមនៅក្នុងដំណើរការនៃអង្គជំនុំជម្រះនេះ ។ វិធានផ្ទៃក្នុងនេះគួរអនុញ្ញាតឱ្យតុលាការដើម្បីជួយជនរងគ្រោះនៅក្នុងលក្ខខណ្ឌរបស់ខ្លួនដោយបង្កើតនីតិវិធីដែលស្វែងរកការចូលរួមពីសំណាក់ជនរគ្រោះកម្ពុជាដែលអវិជ្ជា និងនៅជនបទ ។ ការណ៏នេះ គួរតែនៅក្នុងចំណោមបេសកកម្មនៃអង្គភាពជនរងគ្រោះ (ដែលបានពិគ្រោះយ៉ាងលំអិត) ។

បើគ្រាន់តែដើម្បីប្រជាជនកម្ពុជាដែលរស់នៅទីក្រុង និង រស់នៅឯបរទេស ដែលមានធនធាន ចូលរួមដែរនោះ វានេះអាចឈានទៅដល់ការយល់ឃើញដែលថាតុលាការ គឺសំរាប់អ្នកមាន និងមិនមានយុត្តិធម៌ជាមូលដ្ឋាន នោះទេ។

### ***វិធាន ២៧.៩ សមាគមជនរងគ្រោះ***

វិធាន ២៧.៩ អនុញ្ញាតឱ្យក្រុមនៃជនរងគ្រោះចូលរួមក្នុងនាមជាភាគីរដ្ឋប្បវេណី ។ គណៈកម្មាធិការប្រព្រឹត្តិកម្មស្វាគមន៏វិធាននេះ។ ប៉ុន្តែការណ៏នេះគួរតែធ្វើឱ្យប្រាកដថាសមាគមទាំងនេះគួរតែមិនតំរូវឱ្យចុះបញ្ជីជាមួយរដ្ឋាភិបាល ហើយគួរតែមិនមែនជាកម្មវត្ថុនៃពង្រាងច្បាប់កម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាល និង សមាគមក្នុងស្រុកដែលអង្គការក្នុងស្រុកជាច្រើនមានទស្សនៈថាជាការកំរិតសេរីភាពនៃសមាគមក្នុងស្រុក ។

### ***វិធាន ២៧.១២ ការបង្កើនូវមូលនិធិ និង នីតិវិធីសំរាប់ការគ្រប់គ្រងនូវមូលនិធិនេះ***

យើងយល់ថា បទប្បញ្ញត្តិនៃវិធាននេះដែលទាក់ទងនឹងការជួសជុសការខូចខាត មិនទាន់មានភាពច្បាស់លាស់ និងមិនទាន់គ្រប់គ្រាន់នៅឡើយ ។ ដំណើរការជួសជុលការខូចខាត គឺជាធាតុផ្សំគន្លឹះដើម្បីទទួលជោគជ័យនៃដំណើរការដែលមានគោលបំណងសំខាន់បំផុត គឺការសះជាគ្នា និង ការផ្សះផ្សារជាតិ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មជំរុញឱ្យអង្គជំនុំជម្រះវិសាមញ្ញពិចារណាមូលនិធិតាមបែបគំរូនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លើសពីនេះទៅទៀត តុលាការគួរតែព្យាយាមចុះអនុសារណៈយោគយល់ជាមួយរដ្ឋាភិបាល ដែលបានរឹបអូសទ្រព្យសម្បត្តិដែលនឹងត្រូវតំកល់ទុកនៅក្នុងមូលនិធិនេះ (យោងតាមមាត្រា ៣៩ នៃ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ) ។ បន្ថែមពីនេះទៀតការប្រជុំមួយនៃគណៈកម្មាធិការនីតិវិធី និងវិធាន (ដែលនឹងផ្តួចផ្តើមយ៉ាងឆាប់) គួរតែស្រាវជ្រាវជំរើសដើម្បីគ្រប់គ្រងមូលនិធិ និងបង្កើតក្រុមជំនាញការមួយដើម្បីតាក់តែងគោលការណ៏ដែលទាក់ទងនឹងការជួសជុលការខូចខាត ។ ក្រុមជំនាញការនេះគួរតែត្រូវបានបង្ហាញផ្លូវដោយប្រជាជនកម្ពុជា និង ពឹងផ្អែកលើ *គោលការណ៏ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពី សិទ្ធិដើម្បីទទួលការប៉ះប៉ូវ និង ជួសជុលការអន្តរាយសំរាប់ជនរងគ្រោះនៃអំពើរំលោភបំពានធំៗលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ* របស់អង្គការសហប្រជាជាតិ ។

***វិធាន ១៤ ការចុះបញ្ជីបណ្តឹង និង អង្គភាពគ្រប់គ្រងសំណុំរឿង***

ដូចដែលបានកត់សំគាល់ខាងលើ ការណ៏នេះមិនមានជាក់លាក់ ដើម្បីគិតថាចំនួនដែលជាតំណាងនៃជនរងគ្រោះនឹងអាចសរសេរបណ្តឹងស្វែងរកមេធាវី រឺក៏ប្រគល់បណ្តឹងរបស់ពួកគេទៅតុលាការឡើយ ។ នីតិវិធីដទៃទៀតដែលធ្វើឱ្យងាយស្រួលដល់លទ្ធភាពនៃជនរងគ្រោះ ដើម្បីទំនាក់ទំនងជាមួយតុលាការត្រូវតែបានគេពិចារណា ។ សំណើររបស់គណៈកម្មាធិការប្រព្រឹត្តិកម្មគឺ បានបញ្ជាក់ដូចខាងក្រោមដែលពាក់ព័ន្ធនឹងអង្គភាពជនរងគ្រោះ ។

***វិធាន ១៣, ១៤ និង ៣៨. អង្គភាពជនរងគ្រោះ***

ការផ្តល់ឱ្យនូវសិទ្ធិដល់ជនរងគ្រោះ ដើម្បីចូលរួមក្នុងនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងនាមជាដើមបណ្តឹង និងភាគីរដ្ឋប្បវេណី អង្គការហត្ថលេខីជឿជាក់ថា ជាការណ៏មួយដ៏សំខាន់សំរាប់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីបង្កើតនូវអង្គភាពជនរងគ្រោះមួយតាមគំរូនៃការិយាល័យមេធាវីដែលមានស្រាប់ ។ ដូចគ្នានឹងការិយាល័យមេធាវីការពារដែរ ការិយាល័យរបស់ជនរងគ្រោះ គួរតែទទួលបាននូវស្វ័យយ័តភាពនៃប្រតិបត្តិការថវិកាប្រតិបត្តិការដ៏លើសលប់ និងបេសកកម្មច្បាស់លាស់មួយ ។

យើងយល់ថាថវិការនៃអង្គជំនុំជម្រះវិសាមញ្ញដំបូងនឹងចាំបាច់ត្រូវធ្វើវិសោធនកម្មនៅក្នុងករណីនេះ ហើយគួរតែត្រូវទទួលបាននូវថវិកាបន្ថែម។ បន្ថែមពីនេះទៀតអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាកត់សំគាលថាមានមុខងារពីរផ្សេងគ្នា ដែលចាំបាច់ត្រូវបំពេញដើម្បីអាចឱ្យការការពារ គាំទ្រ និងចូលរួមពីសំណាក់ជនរងគ្រោះ។ ដូចដែលលើកឡើងនេះ គណៈកម្មាធិការប្រព្រឹត្តិកម្មសូមជូនអនុសាសន៏ថា អង្គភាពនេះគួរបែងចែកជាពីរផ្នែក ។

***ការបង្កើតអង្គភាពនៃការចូលរួមរបស់ជនរងគ្រោះ***

ការបង្កើតឡើងនូវអង្គភាពនៃការចូលរួមរបស់ជនរងគ្រោះ ដើម្បីលើកទឹកចិត្តនូវការចូលរួមពីសំណាក់ជនរងគ្រោះដែលជាតំណាង និង ពិតប្រាកដ គួរតែស្ថិតនៅក្នុងអាទិភាពដែលខ្ពស់ជាងគេ នៃអង្គជំនុំជម្រះវិសាមញ្ញ ។ បើសិនជាគ្រាន់តែប្រជាជនកម្ពុជាដែលនៅទីក្រុងមានចំណេះដឹង និង មានធានធានអាចចូលរួមបាន ការណ៏នេះអាចធ្វើខូចខាតយ៉ាងធ្ងន់ធ្ងរដល់ភាពស្របច្បាប់នៃតុលាការចំពោះប្រជាជនដទៃទៀត ដូច្នេះ អង្គភាពជនរងគ្រោះដែលបានកត់សំគាល់នៅក្នុងវិធាន ១៣ គួរតែមានបេសកកម្មជាក់លាក់ជាមួយការចុះទៅដល់បណ្តាខេត្តនានា ដើម្បីចុះបញ្ជី និង កត់ត្រាបណ្តឹង និងពាក្យសុំជាភាគីរដ្ឋប្បវេណីសំរាប់ជនរងគ្រោះ។ លទ្ធភាពនៃការឱ្យមានអង្គភាពជនរងគ្រោះអចិន្ត្រៃយ៏មានការិយាល័យនៅតាមបណ្តាខេត្តនានាគួរតែត្រូវនៃគេពិភាក្សា ។ អង្គភាពនេះគួរតែសហការ ជាមួយនឹងការងាររបស់អង្គភាពចុះបញ្ជីបណ្តឹង (វិធាន ១៤) ។ មុខងាររបស់អង្គភាពទាំងនេះ គួរតែទាក់ទងគ្នារវាងការងារនៃតុលាការទៅនឹងប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅឆ្ងាយពីទីក្រុង និង មានលទ្ធភាពដែលមានកំរិតដើម្បីចូលទៅតុលាការដោយ ខ្លួនឯងបាន ។

ដូច្នេះអង្គភាពជនរងគ្រោះដែលបានកត់សំគាល់ នៅក្នុងវិធាន ១៣ គួរតែមានបេសកកម្មជាក់លាក់ជាមួយការចុះទៅដល់បណ្តាខេត្តនានាដើម្បីចុះបញ្ជី និងកត់ត្រាបណ្តឹង និង ពាក្យសុំជាភាគីរដ្ឋប្បវេណីសំរាប់ជនរងគ្រោះ ។ លទ្ធភាពនៃការឱ្យមានអង្គភាពជនរងគ្រោះអចិន្ត្រៃយ៏មានការិយាល័យនៅតាមបណ្តាខេត្តនានាគួរតែត្រូវនៃគេពិភាក្សា ។ អង្គភាពនេះ គួរតែសហការ ជាមួយនឹងការងាររបស់អង្គភាពចុះបញ្ជីបណ្តឹង (វិធាន ១៤)។ មុខនាទីចំបងរបស់អង្គភាពទាំងពីរគួរតែផ្សារភ្ជាប់ទំនាក់ទំនងការងារនៃអង្គជំនុំជម្រះទៅនឹងប្រជាជនខ្មែរភាគច្រើនដែល រស់នៅក្រៅក្រុង និង ដែលមិនសូវមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីមកតុលាការដោយខ្លួនឯង ។

ក៏ដូចគ្នានេះដែរ ដោយសារតែមិនមានប្រព័ន្ធប្រៃសណីយ៏ដែលដំណើរការល្អ អង្គភាពទាំងពីរត្រូវតែធ្វើការសំរបសំរួលរាល់ចម្លើយរបស់អង្គជំនុំជម្រះទៅកាន់ប្រជាពលរដ្ឋវិញ។ ត្រូវមាននូវកញ្ចប់ថវិការសមល្មមមួយសំរាប់ឱ្យ អង្គភាពទាំងពីរនេះដំណើរការបានត្រឹមត្រូវ ។

ម្យ៉ាងវិញទៀត បើសិនជាការរងគ្រោះត្រូវបានគេចាត់ទុកថាបានចងភ្ជាប់ជាមួយសិទ្ធិទទួលបានសំណងជំងឺចិត្ត វានឹងមានការប្រព្រឹត្តឱកាសនិយមនៅក្នុងកំរិតដ៏ខ្ពស់មួយៈ ឧបាយកលស្វែងរកការតបស្នងជាប្រាក់ជាថ្នូរនឹងការធ្វើលិខិតទាមទារសំណងជំងឺចិត្ត រឺធ្វើការទាមទារក្លែងក្លាយ ។ ផែនការសំរាប់ដោះស្រាយបញ្ហាទាំងនេះគួរចាប់ផ្តើមធ្វើក្នុងពេលនេះតទៅ ។

***អង្គភាពការពារជនរងគ្រោះ***

គណៈកម្មាធិការប្រព្រឹត្តិកម្មផ្តល់អនុសាសន៍ឱ្យបង្កើតអង្គភាពការពារមួយដែលទទួលខុសត្រូវទៅលើវិធានការការពារ និងគាំពារដល់ជនរងគ្រោះ រឺជនរងគ្រោះ និងសាក្សី ។ អង្គភាពបែបនេះអាចជាផ្នែកមួយនៃអង្គភាពជនរងគ្រោះនៃការិយាល័យរដ្ឋបាល ។

ក្នុងករណីដែល អង្គជំនុំជម្រះពិតជាអនុញ្ញាតមានការចូលរួមរបស់ជនរងគ្រោះនៅក្នុងកំរិតខ្ពស់មួយនោះ ជនរងគ្រោះទាំងនេះក៏គួរទទួលបាននូវវិធានការការពារជាចាំបាច់ផងដែរ ។ ត្រូវមានអង្គភាពការពារដ៏ខ្លាំងមួយ ដែលមានថវិកាគ្រប់គ្រាន់សមល្មម ដើម្បីធានាសុវត្ថិភាពរបស់សាក្សី និងជនរងគ្រោះ ។

អង្គភាពការពារនេះត្រូវមានអំណាចទទួលរ៉ាប់រងអនុវត្តវិធានការមួយចំនួន ដូចជា រៀបចំការដឹកជញ្ជូនដោយសុវត្ថិភាពទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ និងការត្រឡប់មកវិញដោយមិនចាំបាច់ស្វែងរកសេចក្តីបង្គាប់ពីសហចៅក្រមស៊ើបអង្កេតពីចៅក្រម និងពីអង្គជំនុំជម្រះ ។ វិធានផ្ទៃក្នុងក៏ត្រូវធ្វើបញ្ជីរៀបរាប់ពីជំនាញចាំបាច់នានា ដែលបុគ្គលិករបស់អង្គភាពការពារជនរងគ្រោះ និងសាក្សី ត្រូវមានដោយសង្កត់ធ្ងន់ទៅលើតំរូវការនៃអ្នកជំនាញខាងផ្នែកសេវាចិត្តវិជ្ជា សង្គម ។ បន្ថែមពីនេះ វិធានផ្ទៃក្នុងត្រូវបង្កើតវិធានការពិសេសសំរាប់ជនរងគ្រោះនៃអំពើរហឹង្សាផ្លូវភេទ កុមារ មនុស្ស ចាស់ និងមនុស្សពិការផងដែរ ។

***ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល***

ត្រូវតែមានជាចាំបាច់នូវវិធានបន្ថែមនានា ដើម្បីបំភ្លឺនូវតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការជួយសំរួលនូវការចូលរួមរបស់ជនរងគ្រោះ ។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា មានចំណាប់អារម្មណ៍ជួយយ៉ាងខ្លាំងដល់តុលាការនៅក្នុងការងារនេះទៅតាមកំរិតនៃធនធានដែលមាន ។ គណៈកម្មាធិការប្រព្រឹត្តិកម្មជំរុញលើកទឹកចិត្តអង្គជំនុំជម្រះអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមក្នុងការតាក់តែងវិធានទាំងនេះ ។

### ៥. ទម្រង់ និង ការផ្សព្វផ្សាយសាលក្រម

***វិធាន ១០០ : ទម្រង់នៃសាលក្រម***

គណៈកម្មាធិការប្រព្រឹត្តិកម្មស្វាគមន៍ការសំរេចរបស់អង្គជំនុំជម្រះដែលតំរូវឱ្យគ្រប់សាលក្រមរបស់អង្គជំនុំជម្រះត្រូវរួមបញ្ចូលនូវផ្នែកសំអាងហេតុ ដែលពន្យល់អំពីអង្គហេតុ និង អំណះអំណាងផ្នែកច្បាប់ដែលគាំទ្រសេចក្តីសំរេចនោះបន្ថែមពីលើផ្នែកវិនិច្ឆ័យសេចក្តីរបស់អង្គជំនុំជម្រះ ។ គណៈកម្មាធិការប្រព្រឹត្តិកម្មសង្ឃឹមថាការណ៍នេះនឹងជួយបំភ្លឺកាន់តែច្បាស់នូវប្រវត្តិសាស្ត្រកម្ពុជា ។

ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្ម ស្នើថាចំណុចតំរូវខាងលើនេះក៏ត្រូវមានផងដែរចំពោះចៅក្រមដែលមានគំនិតខ្វែង-ចៅក្រមដែលខ្វែងគំនិតនឹងសំអាងហេតុតែព្រមព្រៀងនឹងការវិនិច្ឆ័យទាំងមូល- និង ចំពោះគ្រប់ករណីទាំងអស់ដែលអង្គជំនុំជម្រះមិនអាចឈានទៅដល់ការវិនិច្ឆ័យណាមួយ ។ វិធាន ១០០.២ ត្រូវកែប្រែទៅជា "ប្រសិនបើមិនមានសម្លេងឯកច្ឆន្ទចៅក្រមត្រូវសរសេរអង្គហេតុ និងអំណះអំណាងផ្នែកច្បាប់ដែលគាំទ្រនូវសេចក្តីសំរេចរបស់ខ្លួននៅក្នុងយោបល់ដាច់ដោយឡែកមួយ រឺ នៅក្នុងយោបល់ខ្វែង រឺ ត្រូវចុះហត្ថលេខាលើយោបល់របស់ចៅក្រមផ្សេងទៀត....." ។

ផលប្រយោជន៍នៃយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា តំរូវសាធារណៈជនដឹងពីសំអាងហេតុរបស់ចៅក្រមទាំងអស់ ជាពិសេសសំអាងហេតុរបស់ចៅក្រម ដែលមិនយល់ព្រមនឹងការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ រឺ ដែលមិនអាចរកសំឡេងភាគច្រើនលើសលុបបាន ។

***វិធាន ១០១ : ការប្រកាសសាលក្រមនៅសវនាការសាធារណៈ***

ការប្រកាសសាលក្រមនៅសវនាការសាធារណៈមួយមានសារៈសំខាន់។ ប៉ុន្តែគណៈកម្មាធិការប្រព្រឹត្តិកម្ម គិតទុកជាមុនថា សាលក្រម (និង អាចមានយោបល់ដោយឡែក រឺ យោបល់ខ្វែងនានា) នៅក្នុងរឿងក្តីទាំងនេះនឹងវែងអន្លាយ។ វិធានផ្ទៃក្នុង ក៏ត្រូវតំរូវឱ្យអង្គជំនុំជម្រះផ្សព្វផ្សាយសេចក្តីសំរេចរបស់ខ្លួន និងផ្តល់សេចក្តីសំរេចនេះដល់សាធារណៈជន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងកំឡុងពេល ២៤ម៉ោង បន្ទាប់ពីការប្រកាសសាលក្រមនៅសវនាការជាសាធារណៈ ។

***ការវិនិច្ឆ័យដោយផ្អែកទៅលើចំលើយសារភាព***

គណៈកម្មាធិការប្រព្រឹត្តិកម្មទទួលស្គាល់ថា ដំណើរការក្តីព្រហ្មទណ្ឌដោយមានការទទួលកំហុសមិនមាននៅក្នុងនីតិវិធីធម្មតានៃប្រព័ន្ធច្បាប់សរសេរនោះទេ ថ្វីបើតុលាការអន្តរជាតិដទៃទៀតបានទទួលស្គាល់ក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងករណីដែលរឿងក្តីមួយត្រូវបានដោះស្រាយ ដោយសារតែជនជាប់ចោទបានទទួលថា បានប្រព្រឹត្តបទល្មើស វាទាមទារជនជាប់ចោទនោះទទួលស្គាល់នូវវិសាលភាពនៃបទល្មើសនោះទាំងស្រុង។ គេមិនត្រូវទទួលយកការព្រមព្រៀងជាសំងាត់ស្តីពីការសារភាពទេ។

បន្ថែមពីនេះ ដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ ចៅក្រមនៃអង្គជំនុំជម្រះត្រូវប្រាកដថាចំលើយរបស់ជនជាប់ចោទផ្តល់ឱ្យដោយដឹងច្បាស់ និងដោយស្ម័គ្រចិត្ត ។

## ៦. ការជំនុំជម្រះកំបាំងមុខ

***វិធាន ៧៩ : ការជំនុំជម្រះកំបាំងមុខ***

គណៈកម្មាធិការប្រព្រឹត្តិកម្ម មិនយល់ស្របទៅនឹងការប្រើការជំនុំជម្រះកំបាំងមុខនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញឡើយ។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាបានដឹងថា មានករណីខ្លះដែលការជំនុំជម្រះប្រភេទនេះត្រូវបានអនុញ្ញាត។ បន្ថែមពីនេះអង្គការមិនមែនរដ្ឋាភិបាលបានដឹងថា អាចនឹងមានចុងចោទសំខាន់មួយរឺ ច្រើន ភៀសខ្លួនចេញពីប្រទេសដែលអាចនឹងទៅប្រទេសដែលមិនធ្វើបត្យាប័ន។ វាប្រាកដណាស់ដែលការណ៍នេះនឹងក្លាយជាសោកនាដកម្មមួយសំរាប់យុត្តិធម៌នៅកម្ពុជា និងសំរាប់មនុស្សជាតិ ។

យ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្មប្រឆាំងនឹងការប្រើនូវការជំនុំជម្រះប្រភេទនេះ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយសារវានឹងធ្វើឱ្យអន្តរាយដល់ភាពដែលគួរឱ្យជឿជាក់បាននៃអង្គជំនុំជម្រះនេះ និងមិនអាចធ្វើជាគំរូដ៏ល្អមួយសំរាប់ដំណើរការនៃតុលាការសាមញ្ញ។ ការជំនុំជម្រះកំបាំងមុខអាចចាត់ទុកជាការជំនុំជម្រះ ដែលមានលក្ខណៈនយោបាយ និង ដែលខ្វះនូវការធានាភាពយុត្តិធម៌ដ៏ត្រឹមត្រូវ ។

## ៧. ក្រុមប្រឹក្សាធម្មនុញ្ញ

បច្ចុប្បន្ននេះវិធានផ្ទៃក្នុងមិនបាននិយាយពីរបៀបដោះស្រាយបញ្ហាធម្មនុញ្ញភាពទេ។ វិធានផ្ទៃក្នុងត្រូវកំណត់ឱ្យបានច្បាស់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចដោះស្រាយបញ្ហាធម្មនុញ្ញភាព ហើយថា បញ្ហាទាំងនេះមិនចាំបាច់ត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

អង្គជំនុំជម្រះវិសាមញ្ញគឺជាតុលាការវិសាមញ្ញមួយនៅក្នុងតុលាការកម្ពុជា ហេតុដូច្នេះវាចាំបាច់ត្រូវមានការអនុញ្ញាតិនានាដើម្បីឱ្យដំណើរការនេះអាចធ្វើទៅបានល្អ។ វាមិនត្រឹមត្រូវទាល់តែសោះដែលបញ្ហានានាដែលកើតមាននៅក្នុងរង្វង់អង្គជំនុំជម្រះត្រូវដោះស្រាយដោយតុលាការកម្ពុជាដទៃទៀត ដោយរួមទាំងក្រុមប្រឹក្សាធម្មនុញ្ញផងដែរ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មផ្តល់អនុសាសន៍ថា បន្ថែមពីលើការកែប្រែវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើអនុសារណៈយល់ដឹងមួយជាមួយក្រុមប្រឹក្សាធម្មនុញ្ញស្តីពីការដោះស្រាយវិវាទទាក់ទិននឹងធម្មនុញ្ញភាព ។

## ៨. ការបកប្រែភាសា

### *វិធាន ៣៥ : អ្នកបកប្រែ*

ការបកប្រែភាសាដ៏មានគុណភាពខ្ពស់ គឺជាចំណុចមួយនៃចំណុចនានា ដែលនាំទៅដល់ជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញ។ ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ សាក្សី និង ជនរងគ្រោះ គួរទទួលបានដំណឹងជាមុនពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានការបកប្រែ មុនពេលដែលការសួរចំលើយចាប់ផ្តើម ។ បន្ថែមពីនេះ វិធាន ៣៥ ត្រូវប្តូរទៅជា "ក្នុងករណីចាំបាច់ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត *មេធាវីការពារជនជាប់ចោទ រឺមេធាវីជនរងគ្រោះ* ត្រូវប្រើអ្នកបកប្រែ ។ *គ្រប់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ សាក្សី រឺ ភាគី ត្រូវ*ទទួលបានអ្នកបកប្រែនៅពេលដែល*ស្នើសុំ* ។"

## ៩. ការការពារបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញ ជនរងគ្រោះ សាក្សី និង ជនជាប់ចោទពីបណ្តឹងព្រហ្មទណ្ឌចំពោះការជេរប្រមាថ និង បរិហាកេរ្តិ៍

ដើម្បីឱ្យអង្គជំនុំជម្រះវិសាមញ្ញដំណើរការបានល្អ គ្រប់បុគ្គលដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការនេះ ត្រូវមានសេរីភាពក្នុងការនិយាយស្តី។ ជាពិសេស ជនរងគ្រោះ និង សាក្សីមិនត្រូវខ្លាចការសងសឹកតាមរយៈបណ្តឹងព្រហ្មទណ្ឌពីបទជេរប្រមាថនិងបរិហាកេរ្តិ៍នោះទេ។ ខណៈដែលការផ្តល់សក្ខីភាពក្លែងត្រូវផ្តន្ទាទោសការចូលរួមរបស់ជនរងគ្រោះនឹងត្រូវទទួលរងឥទ្ធិពលមិនល្អប្រសិនបើដំណើរការក្តីដែលពាក់ព័ន្ធនោះមិនស្ថិតនៅតែក្នុងរង្វង់យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ហេតុដូច្នេះ យ៉ាងហោចណាស់ វិធានផ្ទៃក្នុងត្រូវអនុម័តយកនីតិវិធីមួយដែលធានាថាករណីផ្តល់សក្ខីភាពក្លែង រឺការភូតភរនឹងមិនត្រូវដោះស្រាយដោយតុលាការសាមញ្ញកម្ពុជា រឺ ដោយអាជ្ញាធរផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជាឡើយ តែធានាថាគ្រប់ករណីទាំងអស់នេះត្រូវស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គណៈកម្មាធិការប្រព្រឹត្តិកម្មក៏ស្វាគមន៍ផងដែរនូវវិធានការផ្សេងទៀត ដែលធានាសេរីភាពក្នុងការបញ្ចេញមតិនៃបុគ្គលិករបស់អង្គជំនុំជម្រះ ជនរងគ្រោះ សាក្សី និង ជនជាប់ចោទ ។

## សំណើរផ្សេងទៀត

### *វិធាន ១០. ការិយាល័យរដ្ឋបាល*

វិធានផ្ទៃក្នុងនេះបង្កើតនូវតុល្យភាពដ៏ល្អមួយរវាងភាពជាអ្នកដឹកនាំរបស់តុលាការទៅលើដំណើរការតុលាការ និងតួនាទីរបស់ការិយាល័យរដ្ឋបាល។ យ៉ាងណាក្តី វិធានក៏ត្រូវគូសសំគាល់អំពីអព្យាក្រឹតភាពនៃការិយាល័យរដ្ឋបាល និង ត្រូវចាត់ទុកការិយាល័យមេធាវីការពារក្តី និង អង្គភាពជនរងគ្រោះជាអង្គភាព ដែលត្រូវទទួលការជួយជ្រោមជ្រែង។ (តើនេះចង់សំដៅថាអង្គភាពទាំងពីរជាអង្គភាពរបស់ការិយាល័យរដ្ឋបាលតែឯករាជពីការិយាល័យរដ្ឋបាល ហើយការិយាល័យរដ្ឋបាលត្រូវផ្តល់ការជួយជ្រោមជ្រែង និង មិនមែនមានអំណាចគ្របដណ្តប់ទាំងមូល?) ។

### *វិធាន ១៩. នគរបាលយុត្តិធម៌*

ឃ្លាទីពីរនៃកថាខ័ណ្ឌទី១ ត្រូវកែប្រែបន្តិច ដោយត្រូវសរសេរថា "មន្ត្រីនគរបាលនេះ ធ្វើការស៊ើបអង្កេត *ដោយខ្លួនឯងផ្ទាល់* ក្រោមការណែនាំតែមួយគត់..."។ វិធានផ្ទៃក្នុងត្រូវតែបញ្ជាក់ឱ្យច្បាស់ថា នគរបាលយុត្តិធម៌មិនធ្វើការឱ្យតុលាការ និងមិនអាចធ្វើប្រតិភូកម្មកិច្ចការរបស់ខ្លួនទៅឱ្យអ្នកដទៃដែលនៅក្រោមខ្លួនឡើយ។ អ្នកផ្សេងទាំងនោះនឹង មិនទទួលបាននូវការហ៊ឹកហាត់ដែលផ្តល់ដោយតុលាការដល់នគរបាលយុត្តិធម៌ដើម្បីធានានូវសុច្ចរិតភាពនៃដំណើរការក្តី (សូមមើលវិធាន ៦៥)

### *ការចូលរួមពីចម្ងាយ*

គ្រប់ផ្នែកទាំងអស់ដែលអនុញ្ញាតឱ្យមានការចូលរួមពីចម្ងាយរបស់ចៅក្រមត្រូវតែកត់សំគាល់ថា ការចូលរួមពីចម្ងាយនេះ នឹងត្រូវអនុញ្ញាតតែនៅក្នុងករណីពិសេសប៉ុណ្ណោះ។ ចៅក្រមត្រូវតែមានវត្តមានដើម្បីអាចពិភាក្សាជាមួយគ្នាទៅវិញទៅមក។ បញ្ហានេះអាចដោះស្រាយបានដោយត្រូវកែប្រែវិធាន ២២ ដោយកំណត់ថា ចៅក្រមអាចចូលរួមពីចម្ងាយបានក្នុងរយៈពេលខ្លីមួយ តែមិនត្រូវឱ្យលើសពី៥ថ្ងៃជំនុំជម្រះជាប់ៗគ្នានោះទេ ។

### *វិធាន ៣៣. សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងរបស់សាក្សី*

វិធាន ៣៣ - ២ ត្រូវតែមានលក្ខណៈដាច់ខាត និង មិនមែនអាស្រ័យទៅលើការសំរេចដោយសារតែក្នុងករណីនេះ សក្ខីភាព ដោយបង្ខំអាចត្រូវបានគេស្វែងរក ។

### *វិធាន ៣៩. ការជ្រៀតជ្រែកចូលទៅក្នុងការងារតុលាការ*

វិធាន ៣៩ - ២ ខ មិនច្បាស់លាស់ ។ តើ "ដោះស្រាយភ្លាមៗ" មានន័យដូចម្តេច ? និង តើផ្នែក (ខ) - សំរាប់ចាត់ការតាមនីតិវិធី - សំដៅអង្គជំនុំជម្រះមួយណា? នីតិវិធីស្តីពីការមិនគោរពចៅក្រមត្រូវតែពន្យល់បន្ថែមឱ្យបានច្បាស់ និងលំអិតដោយមានស្តង់ដារច្បាស់លាស់ ។

### *វិធាន ៥៣. ការអនុវត្តបណ្តឹងអាជ្ញា*

តុលាការកម្ពុជាធម្មតា ផ្តល់ដល់អ្នកប្តឹងនូវសិទ្ធិប្តឹងតវ៉ាលើសេចក្តីសំរេចមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា (ទៅសាលាឧទ្ធរណ៍)។ វិធានផ្ទៃក្នុងមិនបានចងនូវជំរើសបែបនេះ រឺ មិនបានផ្តល់នូវយន្តការប្តឹងតវ៉ាផ្សេងពីនេះ។ នីតិវិធីបច្ចុប្បន្នគ្រាន់តែផ្តោតការយកចិត្តទុកដាក់ទៅលើសិទ្ធិរបស់ជនជាប់ចោទនៅក្នុងវិធាន ៧៤ ឆ ប៉ុណ្ណោះ ។ ជំហររបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម គឺថា មិនត្រូវបើកឱ្យមានបណ្តឹងតវ៉ានឹងសេចក្តីសំរេចមិនបញ្ជូនរឿងឱ្យ ស៊ើបសួរ ។

### *វិធាន ៦១. ការសាកសួរជនត្រូវចោទ -- មរណៈភាពដែលនឹងជិតកើតមានរបស់ជនត្រូវចោទ*

វិធាននេះហាក់មិនចាំបាច់ និង ថែមទាំងបង្កើតឱ្យមានសក្តានុពលច្រើនហួសហេតុដែលអាចនាំឱ្យបំពាន ។ ប្រសិនបើជនត្រូវចោទចង់ផ្តល់ចំលើយនៅដង្ហើមចុងក្រោយរបស់គាត់វាប្រាកដណាស់ដែលអ្នកដែលនៅក្នុងបន្ទប់នោះ (ដោយរួមទាំងបុគ្គលិករបស់តុលាការ) អាចថតសំលេងបាន ។ ប៉ុន្តែមិនត្រូឱ្យមានជនត្រូវចោទណាម្នាក់ត្រូវបានសួរយកចម្លើយដោយមិនមានវត្តមានរបស់មេធាវីខ្លួននោះទេ បើសិនជាគាត់សុំឱ្យមាន ។

### *វិធាន ៨៦. ការពារទំនាក់ទំនងជាសំងាត់*

អភ័យឯកសិទ្ធិរវាងមេធាវី និង កូនក្តី ត្រូវតែគោរពនៅគ្រប់ដំណាក់កាលនៃនីតិវិធី ។ ស្តង់ដារដែលកំណត់ពីអភ័យឯកសិទ្ធិនេះត្រូវតែមានចែងនៅក្នុងវិធានផ្ទៃក្នុង ។

បន្ថែមពីនេះ ការសំងាត់រវាងពេទ្យ និង អ្នកជម្ងឺត្រូវតែការពារ ជាពិសេសនៅត្រង់ករណីសុខភាពផ្លូវចិត្ត ។ ការណ៍នេះមានសារៈសំខាន់ជាពិសេស សំរាប់ជនរងគ្រោះដែលចូលរួមក្នុងឋានៈ ជាសាក្សីនៅពេលកាត់សេចក្តី តុលាការដទៃទៀតបានជួបប្រទះនូវបញ្ហាដែលថា ឯកសារកត់ត្រាពីបញ្ហាចិត្តសាស្ត្រនានាត្រូវបានប្រើ ដើម្បីចោទប្រកាន់សាក្សីដែលធ្លាប់

បានទទួលរងការឈឺចាប់ពីបទល្មើសធ្ងន់ធ្ងរ។ អង្គជំនុំជម្រះវិសាមញ្ញត្រូវការពារការសំងាត់នៃឯកសារទាំងនេះ ដើម្បីធានាការគោរពភាពជាឯកជនរបស់ជនរងគ្រោះ និង ដើម្បីលើកទឹកចិត្តជនរងគ្រោះទាំងនោះឱ្យទទួលយក សេវាចិត្តសាស្ត្រ ។ ចុងបញ្ចប់ ទំនាក់ទំនងសំងាត់ដទៃទៀត (ដោយរួមបញ្ចូលទាំងទំនាក់ទំនងប្ដីប្រពន្ធ) ត្រូវតែទទួលបាននូវការការពារដូចគ្នានេះដែរ ។ វិធាន ២៨ ហាក់កំពុងព្យាយាមដោះស្រាយបញ្ហានេះមួយចំណែក ប៉ុន្តែផលប៉ះពាល់នៃវិធាននេះនៅមិនទាន់ច្បាស់នៅឡើយ ។ ការស្នើសុំការផ្ដល់សក្ខីកម្មដោយមិនចាំបាច់ស្បថ អាចបំពានសិទ្ធិជនជាប់ចោទនៅក្នុង ករណីខ្លះ ។

***វិធាន ៩១. ការស៊ើបអង្កេតបន្ថែមដោយអង្គជំនុំជម្រះនៃសាលាដំបូង***

នីតិវិធីកម្ពុជាបច្ចុប្បន្នមិនអនុញ្ញាតឱ្យចៅក្រមដែលបានធ្វើការស៊ើបអង្កេត សំរេចទៅលើមូលកភាពនៃរឿងក្ដីនោះទេ។ ការណ៍នេះហាក់ផ្អែកទៅលើការពិនិត្យពិច័យ ដែលថាការស៊ើបអង្កេតអាចមានផលប៉ះពាល់ដល់វត្ថុវិស័យភាពរបស់ចៅក្រម ។ ដូច្នេះ វិធាន ៩១ ត្រូវកែប្រែ ដោយត្រូវបញ្ជូនការស្នើសុំស៊ើបអង្កេតបន្ថែមទៅចៅក្រមស៊ើបអង្កេតវិញ ។

***ការបង្កើតអង្គភាពមេធាវី***

គណៈកម្មាធិការប្រព្រឹត្តិកម្ម មានចំណាប់អារម្មណ៍ទៅលើការធានាថាមេធាវីការពារជនជាប់ចោទ និង មេធាវីរបស់ជនរងគ្រោះ ត្រូវជ្រើសរើសទៅតាមលក្ខណៈវិនិច្ឆ័យជ្រើសរើសដូចគ្នា ទទួលប្រាក់បំណាច់ស្មើគ្នា ទទួលបានការហ្វឹកហាត់ស្មើគ្នា និង នៅក្នុងកិតស្តង់ដារនៃវិជ្ជាជីវៈមេធាវីដូចគ្នា ។ ការបង្កើតអង្គភាពមេធាវី នៅក្នុងការិយាល័យរដ្ឋបាល ដើម្បីដោះស្រាយបញ្ហាទាំងនេះ នឹងជួយធានាបាននូវគុណភាពខ្ពស់នៃការតំណាង ។

គណៈកម្មាធិការប្រព្រឹត្តិកម្មចាត់ទុកថាការបង្កើតជាលក្ខណៈវិនិច្ឆ័យពិសេសសំរាប់អង្គជំនុំជម្រះវិសាមញ្ញ នឹងមិន *"ដាក់កំហិតដល់សិទ្ធិមេធាវីកម្ពុជាក្នុងការការពារក្ដីនៅតុលាការផ្សេង"* (ដូចដែលមានចែងនៅក្នុងសេចក្ដីព្រាង) ជាពិសេសប្រសិនបើសេចក្ដីណែនាំអនុវត្តកំណត់នូវលក្ខណៈវិនិច្ឆ័យទទួលយកដាច់ដោយឡែក សំរាប់មេធាវីកម្ពុជា និង មេធាវីបរទេស ដូចដែលតុលាការពិសេសសំរាប់ជំនុំជម្រះបទឧក្រិដ្ឋធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើតបានធ្វើរួចទៅហើយ ។